ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា មហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា

Office of the Council of Ministers
Royal Academy of Cambodia
International Relations Institute of Cambodia

# សារលិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**
**និងជាអនុប្រធានប្រចាំការនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ**

***ឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏ប្រសើរថ្លៃថ្លាប្រកបដោយមនោសញ្ចេតនារំភើបរីករាយយ៉ាងក្រៃលែង នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦១ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីរំភើបឥតឧបមាសូមគោរពជូននូវសព្ទសាធុការពរបវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ ចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីដឹកនាំស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា ឱ្យក្លាយជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រឈានមុខគេទាំងក្នុងក្របខណ្ឌជាតិ និងតំបន់ និងជាស្ថាប័នដែលផ្តល់ធាតុចូលដ៏សំខាន់ជូនរាជរដ្ឋាភិបាល។

ឆ្លៀតឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំសូមគោរពកោតសរសើរដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន** ដែលតែងតែបានយកអស់ឆន្ទៈ មនសិការ បញ្ញាញាណ ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន ព្រមទាំងពុះពាររាល់ការលំបាកគ្រប់បែបយ៉ាងក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ជាពិសេសការស្រាវជ្រាវបញ្ហាព្រំដែនកម្ពុជា-វៀតណាម ដែលត្រូវធ្វើដំណើរដោយយានជំនិះផង ដោយថ្មើរជើងផង ឆ្លងស្ទឹង បឹងបួរ ចូលព្រៃ ឡើងភ្នំ ចុះជ្រោះ ហើយបានឆ្លងកាត់ឧបសគ្គរាប់រយជំពូក ក្នុងគោលបំណងកសាងឯកសារខ្សែបន្ទាត់ព្រំដែនមួយច្បាស់លាស់សម្រាប់កូនខ្មែរជំនាន់ក្រោយ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មីថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមតាមអភិបាល ប្រោះព្រំសព្ទសាធុការពរជ័យចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន និងក្រុមគ្រួសារ** សូមប្រកបទៅដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ និងសហការី។

*រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨*

**ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា**

**បណ្ឌិត គិន ភា**

មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ក្នុងបរិវេណរាជបណ្ឌិត្យសភាកម្ពុជា)
Russian Federation Blvd., Sangkat Kakab, Khan Posenchey, Phnom Penh, Cambodia (in the Compound of the Royal Academy of Cambodia)
Tel/Fax: (855) 23 890 167, E-mail: iric@iric.gov.kh, Website: http://www.iric.gov.kh